ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

អគ្គនាយកដ្ឋានយោធសេវា

នាយកដ្ឋានព័ត៌មាន

លេខ: ០៣៣/....ន·ទ
២០១៦

# សេចក្តីប្រកាសព័ត៌មាន

នាយកដ្ឋានពត៌មាននៃអគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិសូមជម្រាបជូនដំណឹងដល់សាធារណៈជនអោយបានជ្រាបថា តបតាមការអញ្ជើញរបស់ ឯកឧត្តម នាយឧត្តមសេនីយ៍ SERGEI SHOIGU រដ្ឋមន្ត្រីក្រសួងការពារជាតិ សហព័ន្ធរុស្ស៊ី គណប្រតិភូជាន់ខ្ពស់ក្រសួងការពារជាតិ ដឹកនាំដោយ **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា នឹងអញ្ជើញទៅបំពេញ ទស្សនកិច្ចជាមិត្តភាព និងផ្លូវការនៅសហព័ន្ធរុស្ស៊ី នារសៀលថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៦។

ក្នុងអំឡុងពេលបំពេញទស្សនកិច្ចជាមិត្តភាព និងផ្លូវការរយៈពេល៩ថ្ងៃ ពីថ្ងៃទី២៣ ខែមេសា ដល់ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ នៅសហព័ន្ធរុស្ស៊ី ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ទៀ បាញ់** អមដំណើរដោយនាយទាហានជាន់ខ្ពស់ក្រសួងការពារជាតិនឹងអញ្ជើញចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន និង រដ្ឋមន្ត្រីការពារជាតិរុស្ស៊ីក្រៅផ្លូវការព្រមទាំងចូលរួមក្នុងសន្និសីទទីក្រុងមូស្គូលើកទី៥ស្តីពីសន្តិសុខអន្តរជាតិ (Moscow Conference on International Security) នៅទីក្រុងមូស្គូសហព័ន្ធរុស្ស៊ីផងដែរ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦

នាយកដ្ឋានព័ត៌មាន